**ព្រះរាជាណាចក្រកម្ពុជា**

**គណៈកម្មាធិការជាតិបណ្តុះបណ្តាល** **ជាតិ សាសនា ព្រះមហាក្សត្រ**

**National Training Board (NTB)**

# កំណត់ហេតុប្រជុំ

## គណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB)

ឆ្នាំពីរពាន់ប្រាំបី ខែមិថុនា ថ្ងៃទីដប់ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅសាលប្រជុំ A11 នៃទីស្តីការគណៈរដ្ឋមន្ត្រី (វឌ្ឍសភាចាស់) មានបើកអង្គប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាល National Training Board (NTB) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល ។

**<u>សមាសភាពចូលរួម</u>** :

-សមាជិកគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ចំនួន ៣២ រូប (អវត្តមានចំនួន ០៣ រូប និងលោក លោកស្រីអញ្ជើញមកចូលប្រជុំជំនួសចំនួន ០៤ រូប)

- លេខាធិការចំនួន ០៥ រូប

- តំណាងអ្នកពាក់ព័ន្ធចំនួន ១១ រូប

- មន្ត្រីជំនាញ ចំនួន ០៧ រូប

**<u>របៀបវារៈនៃអង្គប្រជុំ:</u>**

១-ប្រកាសបើកអង្គប្រជុំដោយ **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB)

២-របាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការតាមដានសិស្សដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលរយៈពេល០៣ខែក្រោមការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ ( **ឯកឧត្តម ឡៅ ហ៊ឹម** អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជាប្រធានសម្របសម្រួលគម្រោងអភិវឌ្ឍន៍វិស័យអប់រំទី ២ (ESDP II )

៣-ផែនការអភិវឌ្ឍន៍ធនធានមនុស្សដើម្បីអភិវឌ្ឍន៍ការងារ និងមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ( **ឯកឧត្តម ពេជ សោភ័ន** រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជានាយកគម្រោងអភិវឌ្ឍន៍វិស័យអប់រំទី ២ (ESDP II )

៤-គេហទំព័ររបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB’s Website) ( **លោក ញឹប ចំរើន**) នាយកចាត់ការទូទៅនៃក្រុមហ៊ុន RESOLVO Cambodia

៥-ផ្សេងៗ

**<u>របៀបវារៈទី១:</u>**

ជាកិច្ចចាប់ផ្តើម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណចំពោះវត្តមានសមាជិក សមាជិកានៃអង្គប្រជុំទាំងអស់ និងមានប្រសាសន៍លើកយកបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការងារជាអាទិភាពនាពេលខាងមុខ ជាពិសេសការងារពាក់ព័ន្ធការបណ្តុះបណ្តាលធនធានមនុស្ស និងការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យផ្សារភ្ជាប់នឹងទីផ្សារការងារជាគោលដៅធំ ដែលស្ថិតក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

**<u>របៀបវារៈទី២:</u>**

បន្ទាប់មក ឯកឧត្តមប្រធានអង្គប្រជុំក៏បានអនុញ្ញាតឱ្យ ឯកឧត្តម ឡៅ ហ៊ុម ធ្វើការបង្ហាញរបាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការតាមដានការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ក្រោយពេលបញ្ចប់បាន ០៣ ខែ ហើយ ឯកឧត្តម ឡៅ ហ៊ុម បានបង្ហាញលើចំនុចមួយចំនួនដូចតទៅ :

-ការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់នៅ ០៧ ខេត្ត-ក្រុង រួមមាន ខេត្តសៀមរាប បាត់ដំបង កំពត ស្វាយរៀង តាកែវ កំពង់ឆ្នាំង និងខេត្តស្ទឹងត្រែង។ លទ្ធផលសិក្ខាកាមដែលបានបណ្តុះបណ្តាលរួចចាប់ពីឆ្នាំ២០០៦ - ២០០៨ គិតត្រឹមខែ ឧសភា មានចំនួន ៨០.៥៧៩ នាក់ ក្នុងនោះយើងបានធ្វើការបណ្តុះបណ្តាលជា ០៣ ប្រភេទ គឺ តាមសហគមន៍បានចំនួន ៧៧.៣៦៦ នាក់ ចំណាយជាមធ្យម ១៤ដុល្លា/១ម្នាក់ តាមសហគ្រាសបានចំនួន ១.១៨៧ នាក់ ចំណាយជាមធ្យម ១៨១ដុល្លា/១ម្នាក់ និងតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបានចំនួន ២.០២៦ នាក់ ដែលចំណាយជាមធ្យម ១៧០ដុល្លា/១ម្នាក់ សរុបជាមធ្យមភាគតម្លៃសិក្សារបស់សិក្ខាកាមម្នាក់ៗស្មើ ២២.៥២ ដុល្លា

-កំរិតវប្បធម៌នៃសិក្ខាកាមដែលបានធ្វើការស្ទាបស្ទង់ ក្នុងការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ គឺសិក្ខាកាមដែលបានសិក្សាចំណេះដឹងទូទៅចាប់ពីថ្នាក់ទី៥ឡើងទៅមានចំនួន ៦៦.១០% ថ្នាក់ទី៤ចុះមានចំនួន ២៦.៣៩% និងអ្នកដែលមិនមានការសិក្សាទាល់តែសោះមានចំនួន ៧.៥%

-កំរិតប្រាក់ចំណូលនៃសិក្ខាកាមដែលបានលើកឡើងក្នុងចំនួន ១៩៣ នាក់ មានការកើនឡើងជាងមុនការបណ្តុះបណ្តាលចំនួនន ៣០%

-លើកសំណើរថវិកាបន្ថែមចំនួន ៦២០.៧០០ ដុល្លា សំរាប់ការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ឆ្នាំ ២០០៩ ដាក់ជូនអង្គប្រជុំអនុម័ត បន្ទាប់មកនឹងបញ្ជូនឯកសារទាំងនេះទៅ ADB ដើម្បីឯកភាពទៅតាមនីតិវិធី

**<u>ឯកឧត្តម សុខ អានៈ</u>**

-ចាប់អារម្មណ៍លើការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ ចំពោះលទ្ធផលការងារដែលទទួលបានក្រោយពេលបញ្ចប់វគ្គ

-ដូច្នេះក្រោយពីមានការបណ្តុះបណ្តាលរួច យើងឃើញថាប្រាក់ចំណូលរបស់សិស្សបានកើនឡើង៣០% តើគេសិក្សាដូចម្តេចដើម្បីដឹងថាគាត់មានចំណូលកើនឡើង ? ព្រោះវាជាការសំខាន់ណាស់ដែលយើងត្រូវពន្យល់ឱ្យគេយល់ ។ យើងមានភារកិច្ចបង្ហាញថាតើការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់មានសារៈសំខាន់ប៉ុណ្ណាក្នុងការអនុវត្តនយោបាយចតុកោណរបស់យើង

-ស្នើឱ្យឯកឧត្តម ឡៅ ហ៊ុម បង្ហាញឱ្យច្បាស់អំពីការកើនឡើងនៃប្រាក់ចំណូលរបស់គាត់ក្រោយពីមានការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់រួចមក ព្រោះយើងបណ្តុះបណ្តាលសិក្ខាកាមរាប់ម៉ឺននាក់ ដូច្នេះវាមានប្រយោជន៍មែនទែនបើយើងពន្យល់គេឱ្យយល់អំពីអ្វីដែលយើងកំពុងធ្វើ

**<u>ឯកឧត្តម ឡៅ ហ៊ុមៈ</u>**

-អង្កេតនេះគ្របដណ្តប់លើតែលទ្ធផលការបណ្តុះបណ្តាលក្នុងឆ្នាំ ២០០៧ ប៉ុណ្ណោះ ព្រោះការបណ្តុះបណ្តាលបានបញ្ចប់ ១០០% ហើយយើងចាប់ផ្តើមធ្វើការអង្កេតបន្ទាប់ពីបណ្តុះបណ្តាលចប់រយៈពេល **០៣ខែ** ក្រុមការងារបានសួរ តើគាត់មុនចូលរៀនមានប្រាក់ចំណូលប៉ុន្មាន ? រៀនចប់មានប្រាក់ចំណូលប៉ុន្មាន ? ក្រោយពីការធ្វើអង្កេតរួច យើងសង្កេតឃើញថាមានការកើនឡើងចំនួន **៣០%** នៃ ប្រាក់ចំណូល

-នេះជាជំហានទីមួយដែលយើងធ្វើសម្រាប់អ្នកដែលរៀនចប់បានរយៈពេល**០៣ខែ**យើងឃើញថាមានការកើនឡើង**៣០%**ប៉ុន្តែវាអាចកើនឡើងច្រើនជាងនេះទៀតចំពោះជំនាញមួយចំនួនដែលត្រូវការពេលវេលាយូររហូតដល់ពេលប្រមូលផល ដូចជាចិញ្ចឹមគោ ត្រី ជ្រូក ជា ដើម

-ការអង្កេតនេះយើងមិនបានធ្វើទៅលើគ្រប់សិស្សទាំងអស់នោះទេ គឺយើងធ្វើជាលក្ខណៈជ្រើសរើសដោយចៃដន្យ ( Random )

ដោយសារថវិកាយើងនៅមានកំណត់

**ឯកឧត្តម  ពេជ  សោភ័ន**

-បន្ថែមលើរបាយការណ៍របស់ ឯកឧត្តម ឡៅ ហ៊ុម សូមបញ្ជាក់ថានេះជាការធ្វើអង្កេតតាមបែបបរិមាណ (Quantitative Research)

-យើងបានជ្រើសរើសយក ១០% នៃសិក្ខាកាមដែលបានបណ្តុះបណ្តាលទាំង ៧ ខេត្ត-ក្រុង ក្នុងឆ្នាំ ២០០០៧ កន្លងមក។ ជាក់ស្តែងអ្នកដែលត្រូវជ្រើសរើសធ្វើការសម្ភាសន៍មានចំនួន ៤.៦៧៦ នាក់

-យើងមានកំរងសំណួរ (Questionaires) សម្រាប់អ្នកចុះអង្កេត

-យើងបណ្តុះបណ្តាលគ្រូជំនាញទាំង ៧ ខេត្ត-ក្រុង អំពីការអង្កេតមុនចុះទៅប្រមូលព័តិមាន និងមានក្រុមមួយទៀតសម្រាប់ធ្វើការវិភាគតាមវិធីសាស្ត្រ (Quantitative Research) ឱ្យចេញជាលទ្ធផលនេះឡើង

-មានសាលាឧត្តមសិក្សាមួយចំនួន បានប្រកាសថានិស្សិតរៀនចប់មានការងារធ្វើ ៨០%-៩០% ការនិយាយបែបនេះគ្មានមូលដ្ឋានច្បាស់លាស់ទេ ដែលគួរតែមានការវាយតម្លៃអំពីគុណភាពអប់រំទៅតាមសាលាឧត្តមសិក្សាតាមរយៈការអង្កេតច្បាស់លាស់មួយ

-នេះជារបាយការណ៍លទ្ធផលរយៈពេល ០៣ខែ បន្ទាប់ពីការបណ្តុះបណ្តាល យើងនឹងធ្វើការអង្កេតបែបនេះរយៈពេល ០៣ខែក្រោយទៀត បានសេចក្តីថាក្រោយការបណ្តុះបណ្តាល ០៦ខែ ព្រោះ ADB ក៏ចង់ដឹងពីលទ្ធផលដែលទទួលបាន ដើម្បីផ្តល់គម្រោងថ្មីមួយសម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅឆ្នាំក្រោយទៀត

**ឯកឧត្តម  សុខ  អានៈ**

-ការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់នេះ យើងចំណាយអស់ច្រើនណាស់ ដូច្នេះក្នុងនាមយើងជាសមាជិក NTB ត្រូវធ្វើយ៉ាងណាពន្យល់គេឱ្យយល់ថាពេលយើងធ្វើទៅវាបានផលប្រយោជន៍អ្វីខ្លះ?

-ដូចឯកឧត្តម ពេជ សោភ័ន បានលើកឡើងហើយ ការធ្វើ Survey នេះគឺដូចគ្នានឹង Surveyដែល IRI បានធ្វើអំពីការបោះឆ្នោតដែរ ។ ការសិក្សាដែលមានលក្ខណៈវិទ្យាសាស្ត្រដូច្នេះ យើងអាចទុកចិត្តចំពោះលទ្ធផលដែលរកឃើញបាន

**ឯកឧត្តម  ម៉ក់  ម៉ាន់ៈ**

-ចាប់អារម្មណ៍ការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ ពិសេសការធ្វើអង្កេតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យ៉ាងណាមិញដើម្បីឱ្យការអង្កេតនេះកាន់តែមានលក្ខណៈវិទ្យាសាស្ត្រថែមទៀត គួរធ្វើឱ្យគ្រប់ទាំង៧ខេត្ត-ក្រុង ពីព្រោះខេត្តខ្លះវាមានអំណោយផលជាងខេត្តផ្សេងៗទៀតដូចជាខេត្តបាត់ដំបងជាដើម

-តើការបង្ហាញនេះជារបាយការណ៍ប្រចាំខែ ឬប្រចាំឆ្នាំ ? បើប្រចាំខែវាអស្ចារ្យណាស់ព្រោះប្រាក់ចំណូលកើនឡើងខ្ពស់

**ឯកឧត្តម  ឡៅ  ហ៊ុមៈ**

-ការបង្ហាញនេះជារបាយការណ៍ប្រចាំខែ គឺយើងតាមដាន (Follow Up) ជំហានទីមួយនៃការតាមដានក្រោយរយៈពេលបាន ០៣ ខែ

**ឯកឧត្តម  អ៊ុក  សារ៉េតៈ**

-ការបង្ហាញពីរបាយការណ៍ និងស្ថិតិនេះមានអត្ថន័យខ្លាំង ហើយយើងមានសង្ឃឹមច្រើនទៅថ្ងៃមុខ ពីព្រោះយើងពុំដែលមានស្ថិតិអ្វីដែលវាស់ពីកំរិតសេដ្ឋកិច្ចប្រជាជនប្រកបការងារ នេះជាស្ថិតិមួយដែលយើងប្រើ និងវាស់បាននូវកំរិតសេដ្ឋកិច្ច និងល្បឿនសេដ្ឋកិច្ច

-បើយើងមានលទ្ធភាពគួរធ្វើការអង្កេតទៅលើ (Qualitative Research)ទៀត ពីព្រោះវាមានសារៈសំខាន់ណាស់

-តើកំណើននេះឡើងដោយសារអ្វី?ឡើងដោយសារគុណភាព?ឡើងដោយសារបរិមាណច្រើន? ឡើងដោយសារការទាក់ទងទីផ្សារ? ហើយយើងត្រឡប់មកមើលការបណ្តុះបណ្តាលរបស់យើងវិញដើម្បីតម្រង់ទិសឱ្យត្រូវ

**លោកជំទាវ ជូ ប៊ុនអេង:**

នាងខ្ញុំសូមសំណូមពរនូវចំណុចមួយចំនួនដូចខាងក្រោម:

-បើយើងធ្វើការអង្កេត និងវិភាគម្តងទៀតឱ្យច្បាស់ជាងនេះទៅទៀត តើចំណូលដែលបានមកល្អក្នុងរយៈពេល ០៣ ខែ ? តើវាមាន Risk ប៉ុន្មាន? ពីព្រោះការដាំបន្លែពុំអាចដាំដុះពេញមួយឆ្នាំបានទេ ដោយសារតែបន្លែខ្លះដាំតាមរដូវ ។ យើងប្រឈមមុខជាមួយនឹងការនាំចូលពីបរទេសតាំងពី ជី ស្លឹកគ្រៃ ត្រយូងចេកជាដើម

-ត្រូវមានការគាំទ្រពីបរិស្ថានជុំវិញ ដូចជាការគាំទ្រគោលនយោបាយជាតិ ពីសហគមន៍ និងអ្នកដឹកនាំសហគមន៍ អាចធ្វើឱ្យអ្នកដែលបណ្តុះបណ្តាលហើយអាចយកជំនាញនេះទៅប្រើបាន ពីព្រោះមានពេលខ្លះគាត់អត់បានយកទៅប្រើទេដោយសារគ្មានការគាំទ្រពីបរិស្ថានជុំវិញគាត់ ដូចជាទីផ្សារដែលអត់ទទួលយកផលិតផលរបស់គាត់ ឬទីផ្សារមិនអំណោយផលចំពោះផលិតផលរបស់ពួកគាត់

**ឯកឧត្តម សុខ អាន:**

យើងសង្កេតឃើញថា នៅតាមព្រំដែនថៃ វៀតណាម មានការនាំចូលតាំងពីត្រយូងចេក ត្រឡាច ស្លឹកគ្រៃជាដើម ។ តើហេតុអ្វីបានជានៅតំបន់នោះពុំមានការដាំដុះនូវដំណាំទាំងអស់នេះ ?

**ឯកឧត្តម ទៀវ ហុងលី:**

-ការបណ្តុះបណ្តាលជាការវិនិយោគមួយ ។ ជាទូទៅនៅគ្រប់ប្រទេសទាំងអស់ចាត់ទុកថាការបណ្តុះបណ្តាលច្រើនតែជាការវិនិយោគមួយដែលចំណាយលុយកាក់ហើយពិបាកវាស់វែង

-យើងគួរបន្តធ្វើការអង្កេត និងធ្វើស្ថិតិនេះបន្ថែមទៀត ព្រោះការធ្វើស្ថិតិនេះមិនត្រឹមតែបង្ហាញពីលទ្ធផលនៃការវិនិយោគលើវិស័យធនធានមនុស្សទេ គឺបង្កើតឡើងទីមួយអភិបាលកិច្ច និងទីពីរការកាត់បន្ថយភាពក្រីក្រដែលយើងត្រូវមើលទៅលើជ្រុងទាំងពីរនេះ

-បន្តការធ្វើ Survey ជាលក្ខណៈវិទ្យាសាស្ត្រគឺទៅលើជំនាញទាំងអស់ដែលបានបណ្តុះបណ្តាលរួច

-គួរបន្ថែមសំណួរហេតុអ្វីបានជាគាត់កើនប្រាក់ចំណូល?

-គួរបន្ថែមសំណួរតើជំនាញក្នុងចំនួនបណ្តុះបណ្តាលទាំងអស់មានប៉ុន្មានភាគរយយកមកប្រើប្រាស់?

-គួរសិក្សាព័ត៌មានទីផ្សារថាតើខេត្តណាត្រូវការជំនាញអ្វី?

-ប្រសិនបើគាត់យកចំណេះដឹងនេះទៅប្រើតិច សួរថាមូលហេតុអ្វីបានជាគាត់មិនយកចំណេះដឹងទៅប្រើប្រាស់? តើមានឧបសគ្គអ្វី?

**ឯកឧត្តម សុខ អាន:**

ស្នើឱ្យមានក្រុម TENA SURVEY រឹងមាំ និងច្បាស់លាស់

**ឯកឧត្តម សុន គន្ធរ:**

-ការធ្វើស្ថិតិមានការលំបាក ពីព្រោះថវិកាយើងមានតិច

- ដើម្បីកុំឱ្យមានហានិភ័យ ស្ថិតិគួរជ្រើសរើសយកកន្លែងណាដែលមានលក្ខណៈទូទៅជៀសវាងយកកន្លែងដែលល្អស្រាប់

- កន្លែងខ្លះពេលដែលកំពុងបង្រៀនទទួលបានលទ្ធផលតែនៅពេលចប់អ្វីៗក៏ចប់ដែរ ដោយសារតែពួកគាត់ពុំយកជំនាញទាំងនេះទៅអនុវត្តន៍បន្តទៀត

- បញ្ហានៅខេត្តបាត់ដំបងមិនបានដាំដុះ ដូចជា ជី ស្លឹកគ្រៃ ព្រោះតំបន់នោះ គេផ្តោតទៅលើការដាំដុះ ដូចជាពោត ដំឡូងមី ទទួលបានប្រាក់ចំណូលសុទ្ធជាង ០១ម៉ឺនដុល្លា/ឆ្នាំ

- បង្រៀនឱ្យគេចេះធ្វើ ដើម្បីជាអាជីព

- យើងគួររៀបចំប្រព័ន្ធពាណិជ្ជកម្ម គឺស្វែងរកទីផ្សារឱ្យផលិតករ

- យើងត្រូវគាំទ្រផលិតផលខ្មែរ

- NTB គួរជំរុញផ្នែកចិត្តសាស្ត្រ, ពាណិជ្ជកម្ម ដោយផ្សារភ្ជាប់ទីផ្សារទៅនឹងផលិតផល

**ឯកឧត្តម សុខ អានៈ**

តាមគោលការណ៍ភូមិមួយផលិតផលមួយ មានបីធំគឺ :

១- ធ្វើយ៉ាងណាឱ្យមនុស្សផលិត

២- ផលិតរបៀបណាឱ្យត្រូវនឹងបរិបទនៃកន្លែងដែលគាត់រស់នៅ

៣- ធ្វើហើយត្រូវមានកន្លែងលក់

**ឯកឧត្តម ឈឿង យ៉ាណារ៉ាៈ**

-កោតសរសើរអំពីការបង្ហាញរបាយការណ៍របស់ឯកឧត្តម ឡៅហ៊ុម កន្លងមក ហើយនេះជាធាតុចូលដំបូងសម្រាប់ការរៀបចំសកម្មភាពអាទិភាពដើម្បីឈានទៅរៀបចំគោលនយោបាយសម្រាប់អនុវត្តបន្តទៅទៀត

-ចំណុចដែលយើងគួរឱ្យលើកទឹកចិត្ត និង គួរតែជំរុញបន្តទៀត គឺក្រោយពីការបណ្តុះបណ្តាល យើងបានបង្កើតឱកាសសម្រាប់គាត់ឱ្យមានការងារធ្វើ ជាហេតុធ្វើឱ្យគាត់មានប្រាក់ចំណូល

-ឆ្លងតាមការអង្កេតដោយពិនិត្យលើបរិមាណការបណ្តុះបណ្តាលមាន០៣ផ្នែកហើយការបណ្តុះបណ្តាលនេះមានមុខសញ្ញាច្បាស់លាស់ ខ្ញុំយល់ឃើញថាការបណ្តុះបណ្តាលតាមសហគមន៍ គឺបំរើឱ្យទីផ្សារមូលដ្ឋានដែលស្ថិតនៅខាងក្រោម ប៉ុន្តែការបណ្តុះបណ្តាលតាមសហគ្រាស និងមជ្ឈមណ្ឌលអាចផ្តល់ការងារ និងបង្កើតការងារមានក៏រិតខ្ពស់ អាចផ្តល់ឱកាសឱ្យគាត់រកការងារបានធ្វើ និងបង្កើតការងារខ្លួនឯងទៀតផង

- ចង់ឱ្យមានការវិភាគបន្ថែមទៀតលើផ្នែកនិមួយៗ និងចីរភាពនៃចំណូលរបស់គាត់

-ប្រសិទ្ធភាពនៃការវិនិយោគទៅតាមប្រភេទនៃការបណ្តុះបណ្តាលនិមួយៗ ដើម្បីឱ្យយើងតម្រង់ទិសដៅទៅថ្ងៃមុខទៀតថាយើងផ្តោតការបណ្តុះបណ្តាលទៅតាមប្រភេទណាមួយច្បាស់លាស់ជាង

-ដោយការវិនិយោគនៅតាមសហគមន៍ នៅមានប្រសិទ្ធភាពខ្ពស់ ដូច្នោះយើងមិនទាន់អាចធ្វើ Policy Recommendation ឬ Policy Conclusionយ៉ាងណាបានទេ ទាល់តែផ្អែកលើការធ្វើអង្កេតមួយជាន់ទៀត ដែលលំអិតជាងនេះ ហើយមានការអង្កេតតាមប្រភេទនៃការបណ្តុះបណ្តាល ទើបយើងអាចធ្វើការសន្និដ្ឋានថាត្រូវរៀបចំផែនការទៅថ្ងៃមុខយ៉ាងដូចម្តេច

-ចំពោះការលើកឡើងរបស់ឯកឧត្តម ពេជ សោភ័ន ថាគួរឱ្យមានការអង្កេតមួយចំពោះសិស្សដែលបានចេញពីឧត្តមសិក្សាតើមានការងារធ្វើប៉ុន្មានភាគរយ ហើយដោយសារការអង្កេតនេះជាបញ្ហាសំខាន់ ខ្ញុំគិតថា បើសិនជាអាចរៀបចំគម្រោងបាន ដោយធ្វើអង្កេតផ្តោតទៅលើបញ្ហានេះ ប្រើថវិកាក៏រិតក្រោម ១០ម៉ឺនដុល្លា ខ្ញុំនឹងខិតខំប្រឹងប្រែងរកថវិកានេះបាន

**ឯកឧត្តម សុខ អានៈ**

-អរគុណចំពោះ CDC ដែលបានជួយរកទុន ខ្ញុំនឹងឱ្យ ACC ទាក់ទងភ្លាម ព្រោះរឿងនេះសំខាន់ណាស់ គឺយើងអាចប្រៀបធៀបសាលាមួយទៅសាលាមួយទៀតថាតើមានគុណភាពឬអត់ ?

**ឯកឧត្តម ពេជ សោភ័នៈ**

-ការអង្កេតនេះ គឺយើងពុំធ្វើតែ ០១ ខេត្តទេ គឺយើងធ្វើឡើងទាំង ៧ ខេត្ត-ក្រុង ហើយប្រើវិធីសាស្ត្រ Quantitative Methods

-បញ្ហាដែលថាតើចំណូលកើនឡើងដោយសារអ្វី? ទីមួយគឺសំខាន់បំផុតមុននឹងធ្វើការបណ្តុះបណ្តាល យើងធ្វើការសិក្សាស្រាវជ្រាវ

រួចហើយ តើតំបន់ណាត្រូវការជំនាញណា? គឺធ្វើឡើងតាមរយៈភូមិ-ឃុំ មានន័យថាតាមប្រព័ន្ធវិមជ្ឈការ ហើយការធ្វើផែនការ គឺថ្នាក់ភូមិ-ឃុំជាអ្នកធ្វើ ។ ជាពិសេសយើងបានធ្វើ TENA ដើម្បីកំណត់នូវជំនាញ ដែលមូលដ្ឋានចង់បានមុននឹងធ្វើការបណ្តុះបណ្តាលដែលជាហេតុធ្វើឱ្យគាត់ទទួលបានចំណូលកើនឡើង។ ហើយកត្តាមួយចំនួនទៀតដោយសារគុណភាព មានន័យថាពីមុនគាត់ចេះធ្វើដែរតែគ្មានបច្ចេកទេសធ្វើឱ្យគាត់ទទួលបានទិន្នផលទាប ប៉ុន្តែបន្ទាប់ពីធ្វើការបណ្តុះបណ្តាលរួចអាចទទួលបានទិន្នផលខ្ពស់

-បញ្ហាដែលលោកជំទាវ លើកឡើងអំពី Risk យើងបានគិតគូររួចហើយ ដោយយើងមានគម្រោងមួយដែលនឹងបង្រៀនបច្ចេកទេសក្រោយពីប្រមូលផល យើងនឹងបង្រៀនឱ្យគាត់ចេះរក្សាទុក និងវេចខ្ចប់កសិផលឱ្យបានរយៈពេលយូរ និងរក្សាគុណភាពខ្ពស់

-យើងនឹងធ្វើការអង្កេតឱ្យបានទូលំទូលាយជាងការអង្កេតលើកនេះទៀត នៅពេលយើងធ្វើការអង្កេតអំពីលទ្ធផលនៃការបណ្តុះបណ្តាលក្រោយរយៈពេល ៦ខែ ហើយសំណួរផ្សេងៗដែលឯកឧត្តម លោកជំទាវ លើកឡើងយើងនឹងដាក់នៅក្នុងកម្មវិធីលើកក្រោយនេះ

-បញ្ហាមួយទៀតមូលហេតុដែលការបណ្តុះបណ្តាលនៅតាមសហគមន៍តម្លៃឯកតាទាប ព្រោះយើងប្រើរយៈពេលខ្លី ចំនួនសិក្ខាកាមចូលរួមមានចំនួនច្រើន ។ នៅតាមសហគ្រាសវាថ្លៃដោយសារបញ្ជូនសិក្ខាកាមទៅរៀននៅឯកជន ហើយយើងឧបត្ថម្ភជាថវិកា មួយទៀតនៅមជ្ឈមណ្ឌលមុខជំនាញមិនអាចរៀននៅក្រៅបាន ព្រោះនៅមជ្ឈមណ្ឌលមានគ្រឿងម៉ាស៊ីនគ្រប់គ្រាន់ជាងនៅខាងក្រៅ។

ដូចនេះបានជាការបណ្តុះបណ្តាលនៅតាមសហគ្រាស និងមជ្ឈមណ្ឌល មានតម្លៃឯកតាខ្ពស់ ព្រោះវាប្រើរយៈពេលវែងហើយ វាផ្លូវការ (Formal) ជាងនៅតាមសហគមន៍ (Informal)

**<u>លោកជំទាវ ជូ ប៊ុនអេង</u> :**

នាងខ្ញុំបានយល់អំពីការបណ្តុះបណ្តាលនេះហើយ ក៏ប៉ុន្តែមានការបារម្ភនូវចំនុចមួយចំនួនទៅនឹងការបណ្តុះបណ្តាលនេះ គឺ:

-ការបណ្តុះបណ្តាលគួរតែគិតដល់ផលប៉ះពាល់ មានន័យថាមិនបំផ្លាញធម្មជាតិ ហើយអាចជួយការពារភោគផលធម្មជាតិ

- ការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក សម្រាប់ការបណ្តុះបណ្តាលគួរតែមានការអភិរក្ស

- គួរតែផ្តោតការចាប់អារម្មណ៍ទៅលើការបណ្តុះបណ្តាលទាក់ទងនឹងការកែច្នៃផលិតផល

**<u>ឯកឧត្តម សុខ អាន</u> :**

- យើងកំពុងខិតខំជំរុញការកែច្នៃផលិតផលកសិកម្ម
- បច្ចុប្បន្នយើងត្រូវការពេលវេលា ដើម្បីកសាងទំនុកចិត្តរបស់អតិថិជនឱ្យគាំទ្រផលិតផលក្នុងស្រុក
- អនុម័តលើគម្រោងថវិកាស្នើសុំរបស់ឯកឧត្តម ឡៅ ហ៊ីម ដែលបានលើកឡើងក្នុងការបណ្តុះបណ្តាល តាមប្រព័ន្ធលិខិតបញ្ជាក់

**<u>របៀបវារៈទី ៣</u> :**

**<u>ឯកឧត្តម ពេជ សោភ័ន</u>:**

បង្ហាញពីគោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលត្រូវផ្សារភ្ជាប់ទៅនឹងមុខរបរ ចែកចេញជា ៣ ផ្នែកគឺ :

-ស្ថានភាពនៃទីផ្សារការងារ ដែលយើងហៅថាផ្នែកតំរូវការ តើទីផ្សារការងារបច្ចុប្បន្នទៅដល់ណាហើយ? យ៉ាងណា?

-ផ្នែកខាងផ្គត់ផ្គង់ មានន័យថា អ្នកដែលផ្តល់កំលាំងការងារ ឱ្យទីផ្សារការងារដល់ណាហើយ?

-ដំណោះស្រាយ

១- <u>ផ្នែកតម្រូវការកំលាំងពលកម្ម</u>

- ដើម្បីជួយប្រជាពលរដ្ឋឱ្យរួចចាកផុតពីភាពក្រីក្រ យុទ្ធសាស្ត្រអភិវឌ្ឍន៍ ត្រូវសង្កត់ធ្ងន់ទៅលើបញ្ហាសំខាន់ ០៣ គឺ ការផ្តល់ការងារ ការលើកកំពស់ផលិតភាព និងការបង្កើនប្រាក់ចំណូលគ្រួសារ

-មុខរបរ និងការងារ គឺជាផ្លូវដ៏សំខាន់ ដើម្បីឱ្យប្រជាពលរដ្ឋយើងចាកចេញផុតពីភាពក្រីក្រ

-ទិន្នន័យពីក្រសួងផែនការនៅឆ្នាំ ២០០៤ បង្ហាញថាកំលាំងពលកម្មសរុបមានចំនួន ៧,១៦ លាននាក់ ក្នុងនោះវិស័យកសិកម្ម ៦០,៣% ទទួលផលបាន ៣១,៩% នៃGDP វិស័យឧស្សាហកម្ម ១២,៥% ទទួលផលបាន ២៨% នៃGDP និងវិស័យសេវាកម្ម ២៧,២% ទទួលផលបាន ៤០,១% នៃGDP

-ទីផ្សារការងារ មានទំហំធំធេង និងស្មុគស្មាញណាស់ ដោយរាប់ទាំងការងារនៅតាមភូមិ ឃុំតូចៗ រហូតដល់សហគ្រាសធំៗចំរុះជាតិសាសន៍

-កំលាំងពលកម្មរបស់យើងក្នុងពេលបច្ចុប្បន្ន មានច្រើននៅជនបទ ដូចច្នេះយើងមិនត្រូវភ្លេចតម្រូវការរបស់ប្រជាពលរដ្ឋយើងភាគច្រើនដែលត្រូវការជំនាញមូលដ្ឋានសាមញ្ញៗ ដើម្បីបង្កើនជីវភាពគ្រួសារនិមួយៗនោះទេ

-នៅក្នុងឆ្នាំ ២០០៤ ផ្នែកកសិកម្ម កំលាំងពលកម្មរហូតដល់ ៦០% តែបានផ្តល់ចំណែក ៣២%ប៉ុណ្ណោះក្នុង GDP ។ នេះបង្ហាញឱ្យឃើញថាផលិតភាពផ្នែកកសិកម្មនៅមានកំរិតទាប ដែលជាហេតុធ្វើឱ្យពលករផ្នែកនេះមានប្រាក់ចំណូលទាប

-កំណើននាំចូលសំលៀកបំពាក់ និងវាយនភ័ណ្ឌទៅសហរដ្ឋអាមេរិកសម្រាប់កម្ពុជា យើងមានការធ្លាក់ចុះជាលំដាប់ចាប់ពីឆ្នាំ ២០០៥

-កត្តាដែលមានឥទ្ធិពលលើការប្រកួតប្រជែងមាន ក្រដាសស្នាម ការដឹកជញ្ជូន ពេលចុះកុងត្រាធ្វើពាណិជ្ជកម្ម ការធ្វើអធិការកិច្ចផ្សេងៗការទំនាក់ទំនងពលករ និងអ្នកទិញ ។ល ។ ប៉ុន្តែអ្វីដែលសំខាន់ ដែលយើងយកមកពាក់ព័ន្ធនៅទីនេះ គឺផលិតភាពនៃកម្លាំងពលកម្មរបស់យើង ដែលវាជាកត្តាដ៏សំខាន់មួយនៅក្នុងការមានឥទ្ធិពលក្នុងការប្រកួតប្រជែងរោងចក្រកាត់ដេរ

-តាមការសិក្សារបស់យើង ប្រសិទ្ធភាពផលិតកម្ម (Production Efficiency) របស់យើងមានតែពី ៣០% ទៅ ៤០% ចំណែកឯនៅវៀតណាមវិញលើសពី ៦០% ។ ប៉ុន្តែ បើយើងអាចធ្វើឱ្យប្រសិទ្ធភាពផលិតកម្មកើនពី ៣៥% ទៅ ៥៥% នោះប្រាក់ ខែកម្មករ-កម្មការនីកើនឡើង ២ ដង និងប្រាក់ចំណេញនិយោជកកើនឡើង ១០% ។ ដូច្នេះការបង្កើនផលិតភាព គឺជាកត្តាកំនត់នូវជោគជ័យនៃការប្រកួតប្រជែងនេះ ។ កត្តាមួយចំនួនដែលធ្វើឱ្យផលិតភាពទាបគឺ Materials, Labor, Machine, Logistics

-មូលហេតុដែលប្រាក់ខែកម្មករ-កម្មការនីទាបជាងប្រទេសផ្សេងៗ ពីព្រោះមកពីផលិតភាពការងារនៅទាបជាងគេ

-ជាទូទៅ គុណភាព និងកំរិតនៃការអប់រំរបស់កំលាំងពលកម្មបច្ចុប្បន្ន នៅមានកំរិត ព្រោះ ២៣,៧% គ្មានការអប់រំ (មានតិច) និង ៤២,៤% មិនទាន់បញ្ចប់បឋមសិក្សា

-ការសិក្សាពីទីផ្សារការងារ បានបង្ហាញឱ្យឃើញថា ការអភិវឌ្ឍន៍សមត្ថភាពជំនាញរបស់កំលាំងពលកម្មបច្ចុប្បន្ន ជាកត្តាចាំបាច់ដើម្បីបង្កើនផលិតភាព, បង្កើនប្រាក់ចំណូលគ្រួសារ និងកាត់បន្ថយភាពក្រីក្រ

២- <u>ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម</u>

-នៅឆ្នាំ ២០០៦ និស្សិតដែលសិក្សាថ្នាក់បរិញ្ញាប័ត្រនៅសាកលវិទ្យាល័យមានចំនួន ៩៤.៣១០ នាក់ ដែលក្នុងនោះ មាននិស្សិតប្រមាណ ៩២% រៀនមុខជំនាញពាក់ព័ន្ធផ្នែកសេវាកម្ម ៥% ពាក់ព័ន្ធផ្នែកឧស្សាហកម្ម និង ៣% ពាក់ព័ន្ធផ្នែកកសិកម្ម។ ចំណែកសិស្សដែលរៀននៅគ្រឹះស្ថានសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (កំរិតអ្នកបច្ចេកទេស ឬ បរិញ្ញាបត្ររង) មានប្រមាណ តែ១៦.៩១២នាក់ ស្មើនឹង ១៥% ប៉ុណ្ណោះ ។ ដូច្នេះការផ្គត់ផ្គង់កំលាំងពលកម្មពុំទាន់ឆ្លើយតបនឹងតម្រូវការរបស់ទីផ្សារ ការងារនៅឡើយ

- ចាប់ពីឆ្នាំ ២០១១ តទៅ ចំនួនសិស្សថ្នាក់ទី ១២ កើនដល់ ២០១.៨០០ នាក់ ហើយអ្នកជាប់សញ្ញាបត្រទុតិយភូមិឡើងដល់ ១៦១.៤៤០នាក់ ។ រីឯគ្រឹះស្ថានសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេលវែងសព្វថ្ងៃ អាចទទួលសិស្សចូលរៀន បានត្រឹមតែ ៧.០០០នាក់ ក្នុងមួយឆ្នាំ ។ ដូច្នេះការសាងសង់អគារ និងសាលាបន្ថែមទៀតជាការចាំបាច់ខានពុំបាន

-ដើម្បីដោះស្រាយការងារសមស្របដល់យុវជន និងយុវនារី ក៏ដូចជាដើម្បីផ្តល់ឱ្យទីផ្សារការងារនូវកំលាំងពលកម្មដែលមានសមត្ថភាពជំនាញសមស្របការអភិវឌ្ឍន៍ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ពិតជាអាទិភាព និងចាំបាច់ខានពុំបាន

៣- ដំណោះស្រាយ

- ការអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវផ្តល់អាទិភាពលើការងារដូចខាងក្រោម :

ក-ផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ប្រជាពលករនៅជនបទ ដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ ដូចជាមូលនិធិជាតិបណ្តុះបណ្តាល (NTF), និងកម្មវិធីបណ្តុះបណ្តាលតាមលិខិតបញ្ជាក់ (Voucher Skills Training Program) ដែលកំពុងធ្វើសាកល្បងក្នុង ៧ខេត្ត-ក្រុង នៅពេលនេះជាដើម

ខ-ផ្តល់ការបណ្តុះបណ្តាល ឬ វិក្រិតការដល់ពលករនៅតាមរោងចក្រ សហគ្រាស ដើម្បីបង្កើនផលិតភាពនៃការងារ

គ-យកចិត្តទុកដាក់ និងជំរុញការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ឃ-បញ្ចូលក្នុងកម្មវិធីសិក្សានូវការបណ្តុះបណ្តាល " សហគ្រិនភាព" ដើម្បីឱ្យសិក្ខាកាម សិស្ស និស្សិត អាចបង្កើតការងារថ្មី ឬ ប្រកបមុខរបរដោយខ្លួនឯង

ង- សម្របសម្រួលផ្តល់ឥណទានខ្នាតតូចឱ្យសិស្សពេលរៀនចប់ ដើម្បីបង្កើត ឬ ប្រកបមុខរបរ/ការងារដោយខ្លួនឯង

ច-ការធានាគុណភាពបណ្តុះបណ្តាល ដោយមានការចូលរួមពីផ្នែកឯកជន និយោជក សហគមន៍ និងសិក្ខាកាម ព្រមទាំងការវាយតំលៃគុណភាពត្រូវផ្អែកលើលទ្ធផល

ឆ-បង្កើតប្រព័ន្ធក្របខណ្ឌគុណវុឌ្ឍជាតិ ស្តង់ដារជាតិសមត្ថភាព និងការធ្វើតេស្ត ដើម្បីធានាគុណភាពការបណ្តុះបណ្តាល

ជ-ដើម្បីសម្រួលឱ្យយន្តការព័ត៌មានទីផ្សារដំណើរការបានល្អប្រសើរ យើងបាននឹងកំពុងរៀបចំបង្កើតទីភ្នាក់ងារជាតិមុខរបរ និងការងារដែលក្នុងនោះយើងបានបង្កើត Job Centers ចំនួន ០៩ នៅតាមគ្រឹះស្ថានសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ០៨(NTTI, PTCតាកែវ ,កំពត ,ក្រុងព្រះសីហនុ ,សៀមរាប,កំពង់ចាម,ស្វាយរៀង , បាត់ដំបង ) និងក្នុងទីតាំងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ០១កន្លែងទៀត ហើយក្នុងរចនាសម្ព័ន្ធ Job Centers យើងមានផ្នែក ០៣ គឺ E-Center Unit, Library Unit and Counseling Unit ។ យើងបានប្រើគេហទំព័ររបស់ NTB (http://www.ntb.gov.kh) ដើម្បីសម្រួលការជួបគ្នារវាងអ្នកស្វែងរកការងារ និងនិយោជក

ឈ-ភាពដៃគូរវាងវិស័យឯកជន និងសាធារណៈ

-ការអភិវឌ្ឍន៍ធនធានមនុស្សត្រូវផ្អែកលើការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ប្រទេសកម្ពុជាយើង

-ការអភិវឌ្ឍន៍ធនធានមនុស្ស គឺជាកត្តាកំណត់ និងជាគន្លឹះនៃការអភិវឌ្ឍន៍កម្ពុជាប្រកបដោយចីរភាព និងនិរន្តភាព

**ឯកឧត្តម សុខ អាន**

-គោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្សារភ្ជាប់ទៅនឹងទីផ្សារការងារ ដែលយើងសន្មតថា ជាគោលនយោបាយរបស់រាជរដ្ឋាភិបាលតទៅមុខទៀត ហើយនេះជាបញ្ហាសំខាន់ និងជាបញ្ហាគន្លឹះមួយទៅថ្ងៃអនាគត

- នេះជាផ្នែកមួយធំនៃការអភិវឌ្ឍន៍ធនធានមនុស្ស

- គោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈមិនអាចកាត់ផ្តាច់ពីគោលនយោបាយធនធានមនុស្សជារួមទេ

- អនុម័តលើរបាយការណ៍ និងគោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានលើកឡើងរបស់ឯកឧត្តម ពេជ សោភ័ន

**របៀបវារៈទី ៤ :**

**លោក ញឹប ចំរើនៈ**

- បង្ហាញពីគេហទំព័ររបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល (http://www.ntb.gov.kh) ដែលមានប្រាំផ្នែកគឺ :

១- គេហទំព័ររបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាលផ្ទាល់ (NTB)

២- គេហទំព័ររបស់ TVET (Technical Vocational Education and Training )

៣- Job Prospected

៤- Employment

៥- Job Shop

ទន្ទឹមនឹងនេះ លោក ញឹប ចំរើន បានលើកឡើងពីបញ្ហាមួយចំនួនពាក់ព័ន្ធនឹងគោលការណ៍ចំណាយ ដើម្បីសុំឱ្យអង្គប្រជុំសម្រេចដោយក្នុងនោះ បើយើងដាក់ Server នៅក្រុមហ៊ុន RESOLVO ត្រូវចំណាយ $500/month , ក្រុមហ៊ុន Camnet 1,300$/month និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ 2,500$/month

**ឯកឧត្តម ពេជ សោភ័នៈ**

-ស្នើអង្គប្រជុំផ្តល់យោបល់ គួរជ្រើសរើសយកក្រុមហ៊ុនណាសម្រាប់ដួលបង្ហោះគេហទំព័ររបស់យើង

**ឯកឧត្តម សុខ អានៈ**

-តើអង្គប្រជុំរបស់យើងយល់យ៉ាងម៉េចចំពោះបញ្ហាគេហទំព័ររបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល (http://www.ntb.gov.kh)

**ឯកឧត្តម ខៅ ហុងលីៈ**

-ក្រុមហ៊ុន Singapore ដែលចំណាយ ៥០០ ដុល្លា តើ Speed របស់វាយ៉ាងដូម្តេច? ព្រោះ Speed នេះជាបញ្ហាសំខាន់ណាស់

-យើងគួរតែនិយាយគ្នាឱ្យបានច្បាស់លាស់មុននឹងចុះកិច្ចសន្យា ព្រោះវាអាចនឹងមានបញ្ហា

**ឯកឧត្តម ឡា ណារ៉ាតៈ**

-ករណីដែលក្រុមហ៊ុន Singapore ដែលចំណាយ ៥០០ ដុល្លា នោះគួរយើងពិនិត្យទៅលើប្រព័ន្ធគ្រប់គ្រងផង មិនដឹងថាក្រុមហ៊ុននោះស្របច្បាប់ ឬមិនស្របច្បាប់?

-ចំពោះក្រុមហ៊ុន Camnet ជាសហគ្រាសសាធារណៈកំពុងរៀបចំបណ្តាញសេវាថ្មីដើម្បីរៀបចំបញ្ចុះតំលៃប្រើប្រាស់ឱ្យបានថោក

**ឯកឧត្តម សុខ អានៈ**

-បញ្ហាគេហទំព័រនេះ យើងមិនអាចសំរេចបានភ្លាមៗទេ យើងនឹងឱ្យខាង NIDA សហការ និងពិចារណាម្តងទៀត ហើយមានការអ្វីយើងនឹងពិគ្រោះជាមួយឯកឧត្តម ឡា ណារ៉ាត ទៀត

**ឯកឧត្តម សុន គន្ធះ**

-យើងគួរពិចារណាទៅលើគេហទំព័រនេះ តើយើងគួរសរសេរជាភាសាខ្មែរ និងភាសាអង់គ្លេសផង ព្រោះយើងធ្វើឡើងសម្រាប់សិស្ស-និស្សិត និងប្រជាពលរដ្ឋខ្មែរ

**ឯកឧត្តម ម៉ក់ វ៉ាន់**

-ចំពោះព័តិមានដែលបញ្ចូលនៅក្នុងគេហទំព័រទាំងអស់ យើងត្រូវគិតគូរពីបញ្ហាសន្តិសុខសុវត្ថិភាពឱ្យបានគ្រប់គ្រាន់

**ឯកឧត្តម ឈៀង យ៉ាណារ៉ា**

-បញ្ហាគេហទំព័រនេះ CDC មានបទពិសោធន៍ហើយ ដូច្នេះ យើងត្រូវពិភាក្សាជាមួយជំនាញការឱ្យបានច្បាស់លាស់ជាមុន

-ការពឹងពាក់គេ ដើម្បីរៀបចំ Program នេះ យើងត្រូវតែនិយាយដាក់លក្ខខណ្ឌឱ្យបានច្បាស់ជាមុនសិន ព្រោះវាមានសារៈសំខាន់ណាស់ ពេលដែលមានបញ្ហា តើគេអាចដោះស្រាយបានភ្លាមៗឬទេ ? ជៀសវាងពេលយើងត្រូវការកែបន្តិចបន្តួចត្រូវហៅគេរហូត

**ឯកឧត្តម ម៉ឺន តារិន :**

-ក្រុមហ៊ុន Camnet បានតម្រូវឱ្យទិញសម្ភារៈមួយចំនួន ហើយបានចុះកិច្ចសន្យា តែទីបំផុតមិនអាចប្រើប្រាស់ Internet សម្រាប់បណ្តុះបណ្តាលសិស្ស បាននៅពេលមានបញ្ហាសាលាហៅមកជួយដោះស្រាយ តែក្រុមហ៊ុនមិនបានមក ។

-បញ្ហាមួយទៀតគឺអគ្គិសនី នៅពេលបិទអត់ប្រាប់ នាំឱ្យខូចសម្ភារៈ និងឧបករណ៍ប្រើប្រាស់ដែលមានតំលៃខ្ពស់

**ឯកឧត្តម ឡា ណារ៉ាត :**

-ករណីនេះយើងទទួលស្គាល់ ប៉ុន្តែមុនបំណាច់ឆ្នាំ ២០០៩ យើងនឹងប្រសើរឡើងវិញហើយតំលៃថោកទៀត ដូចដែលយើងបានកំពុងបង្កប់ខ្សែអុបទិចពាសពេញប្រទេសបច្ចុប្បន្ន ហើយក៏ចង់ផ្តោតកន្លែងណាមានប្រើទូរស័ព្ទ ទីនោះមានប្រើ Internet ដែរ

**លទ្ធផលនៃអង្គប្រជុំ**

-អនុម័តលើរបាយការណ៍លទ្ធផលនៃការងាររបស់ NTB (ការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់) និងផែនការថវិកាបណ្តុះបណ្តាលតាមលិខិតបញ្ជាក់ឆ្នាំ ២០០៩

-អនុម័តទៅលើផែនការអភិវឌ្ឍន៍ធនធានមនុស្សដើម្បីអភិវឌ្ឍន៍ការងារ និងមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្សារភ្ជាប់ទៅនឹងទីផ្សារពលកម្មបច្ចុប្បន្ន ។ ផ្សព្វផ្សាយកិច្ចប្រជុំនេះតាមទូរទស្សន៍ ដើម្បីបង្ហាញជូនសាធារណៈជនពីខ្លឹមសារនៃ ការងាររបស់ NTB ដែលផ្សារភ្ជាប់នឹងទីផ្សារការងារ

-ករណី Website របស់ NTB នេះយើងបន្តការពិភាក្សាគ្នាតទៅទៀតលើជំរើសបីដែលបានលើកឡើង នឹងមានការអញ្ជើញអ្នកជំនាញការពីស្ថាប័នដែលពាក់ព័ន្ធមកចូលរួមជជែកគ្នាថាតើត្រូវជ្រើសរើសយកមួយណា

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងជំនាញការជាតិដែលបានចូលរួមចំណែកផ្តល់យោបល់ ក៏ដូចជាចែករំលែកបទពិសោធន៍ការងារកន្លងមក និងអនុសាសន៍ល្អៗ ដល់ដំណើរការនៃការអនុវត្តន៍គម្រោងនេះ។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១៣ : ០០ ថ្ងៃត្រង់ នាថ្ងៃខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយស្និទ្ធស្នាល និងទទួលបានលទ្ធផលផ្លែផ្កាគួរជាទីពេញចិត្ត ។

លេខាកត់ត្រា

បានឃើញ និង ឯកភាព

ប្រធានអង្គប្រជុំ

**ហ៊ីង ស៊ីដេត**